# នីតិអន្តរជាតិសាធារណៈ

# PUBLIC INTERNATIONAL LAW

## មេរៀនទី ២

LECTURE 2

## ប្រភពនៃនីតិអន្តរជាតិសាធារណៈ

SOURCES OF PUBLIC INTERNATIONAL LAW

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្តីផ្តើម
- ផ្នែកទី២ សន្ធិសញ្ញា
  - សញ្ញាណទូទៅ
  - ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ
- ផ្នែកទី៣ ទំនៀមទំលាប់
- សញ្ញាណទូទៅ
- ផ្នែកទី៤ គោលការណ៍ទូទៅនៃនីតិ
  - សញ្ញាណទូទៅ
- ផ្នែកទី៥ កិច្ចឯកតោភាគី
  - សញ្ញាណទូទៅ

# កម្មវត្ថុនៃមេរៀន

មេរៀនស្តីអំពី ប្រភពនៃនីតិអន្តរជាតិសាធារណៈមានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពី៖

- អ្វីទៅជាប្រភពនីតិអន្តរជាតិសាធារណៈ
- អ្វីខ្លះជាប្រភពនៃនីតិអន្តរជាតិសាធារណៈ
- យល់ដឹងពីប្រភពនីមួយៗនៃនីតិអន្តរជាតិសធារណៈ
- តើប្រភពនីមួយៗត្រូវគោរពលក្ខខណ្ឌអ្វីខ្លះ
- យល់ពីអត្ថប្រយោជន៍នៃប្រភពនីមួយៗ

# ផ្នែកទី១ សេចក្តីផ្តើម

សូមកុំមានការភាន់ច្រឡំគ្នារវាងពាក្យថា ប្រភព និងពាក្យថា ប្រភពនៃនីតិ។ អ្នកសិក្សាអាចនឹងច្រឡំថា ប្រភពនៃនីតិ គឺជាប្រភពដើមនៃនីតិ នេះគឺជាការយល់ខុស ព្រោះពាក្យថា ប្រភពនៃនីតិគឺមានន័យថា ជាបណ្តាលបទដ្ឋានដែលនៅជាធរមាន ឬត្រូវបានគេកំពុងតែអនុវត្តនៅក្នុងប្រទេសណាមួយ តំបន់ណាមួយ ឬនៅក្នុងសង្គមអន្តរជាតិ។

# ផ្នែកទី១ សេចក្ដីផ្ដើម

ដូច្នេះ ពាក្យថាប្រភពនៃនីតិអន្តរជាតិ គឺជាបណ្តាលវិធាន ឬក៏ជាបទដ្ឋានដែលកំពុងអនុវត្តនៅក្នុងសង្គមអន្តរជាតិ ហើយដែលប្រភពនៃនីតិអន្តរជាតិទាំងនេះ ត្រូវបានចែកនៅក្នុងមាត្រា៣៨ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ។ សូមបញ្ជាក់ថា មាត្រា៣៨ លក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ មិនបានកំណត់ពីឋានានុក្រមនៃប្រភពទាំងនេះឡើយ។

# ផ្នែកទី១ សេចក្តីផ្តើម

នោះប្រសិនបើ យើងនិយាយអំពីប្រភពនៃនីតិអន្តរជាតិសាធារណៈក៏ដូចជាមែកធាងនៃនីតិផ្សេងទៀតដែរ គឺតែងតែមានប្រភពផ្ទាល់ខ្លួនរបស់វាជាក់លាក់។

នីតិអន្តរជាតិសាធារណៈមានប្រភពរបស់ខ្លួន ដែលក្នុងនោះរួមមាន៖ ប្រភពចម្បង និងប្រភពបន្ទាប់បន្សំ ឬគេអាចនិយាយបានថា ប្រភពនៃនីតិអន្តរជាតិមាន ប្រភពជាលាយលក្សអក្សរ និងប្រភពមិនមែនជាលាយលក្ខអក្សរ។

# ផ្នែកទី១ សេចក្ដីផ្ដើម

គេក៏អាចនិយាយបានថា នីតិអន្តរជាតិសាធារណៈមានប្រភពចំនួនបួន។

ប្រសិនបើយើងនិយាយពី ប្រភពចម្បងនៃនីតិអន្តរជាតិសាធារណៈរួមមាន សន្ធិសញ្ញា និងទំនៀមទំលាប់។ ហើយបើយើងនិយាយពីប្រភពបន្ទាប់បន្សំរួមមាន គោលការណ៍ទូទៅនៃនីតិ និងកិច្ចឯកតោភាគី។

# ផ្នែកទី១ សេចក្ដីផ្ដើម

បើយើងនិយាយអំពីប្រភពជាលាយលក្ខអក្សរ រួមមាន សន្ធិសញ្ញា និងកិច្ចឯកតោភាគី និងប្រភពមិនលាយលក្ខអក្សររួមនា ទំនៀមទំលាប់ និងគោលការណ៍ទូទៅនៃនីតិ។

ដូច្នេះ ប្រភពនៃនីតិអន្តរជាតិរួមមានដូចជា សន្ធិសញ្ញា ទំនៀមទំលាប់ គោលការណ៍ទូទៅនីតិ និងកិច្ចឯកតោភាគី។

# ផ្នែកទី១ សេចក្តីផ្តើម

សូមបញ្ជាក់ថា មាត្រា៣៨ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ មិនបានកំណត់ពីឋានានុក្រមនៃប្រភពនៃនីតិអន្តរជាតិសាធារណៈទាំងនេះឡើយ។

នៅក្នុងមាត្រា៣៨ នៃលក្ខន្តិកៈរបស់តុលាការនេះផងដែរ ពុំមានចែងអំពីកិច្ចឯកតោភាគីនោះទេ។

# ផ្នែកទី២ សន្ធិសញ្ញា

សន្ធិសញ្ញា ជាប្រភពដ៏មានសារៈសំខាន់នៃនីតិអន្តរជាតិសាធារណៈ។ តាមរយៈការចូលរួមទៅក្នុងសន្ធិសញ្ញាអន្តរជាតិ ក្នុងនាមរដ្ឋអធិបតេយ្យ រដ្ឋសម្តែងចន្ទៈដោយគ្មានមន្ទិលរបស់ខ្លួន ដោយគ្មានការបង្ខិតបង្ខំពីសំណាក់រដ្ឋ ឬពីស្ថាប័នអន្តរជាតិណាមួយឡើយ។

# ផ្នែកទី២ សន្ធិសញ្ញា

យើងនឹងធ្វើការសិក្សាដោយសង្ខេបទៅលើចំណុចមួយចំនួននៃសន្ធិសញ្ញា ដែលចំណុចទាំងនោះរួមមានដូចជា៖ សញ្ញាណទូទៅនៃសន្ធិសញ្ញា លក្ខខណ្ឌសុពលភាពនៃសន្ធិសញ្ញា អានុភាពគតិយុត្តនៃសន្ធិសញ្ញា និងចុងបញ្ចប់ ឬការផុតរលត់នៃសន្ធិសញ្ញា។

# សញ្ញាណទូទៅ

បើយើងនិយាយអំពីសន្ធិសញ្ញា គឺជាកិច្ចព្រមព្រៀងអន្តរជាតិ ដែលត្រូវធ្វើឡើងនៅក្នុងទម្រង់ជាលាយលក្ខអក្សរ ហើយនិងត្រូវធ្វើឡើងរវាងតួអង្គនៃនីតិអន្តរជាតិ ដែលក្នុងនោះវាងអាចត្រូវបានធ្វើឡើងរវាងរដ្ឋ និងរដ្ឋ ឬ/និងរវាងរដ្ឋ និងអង្គការអន្តរជាតិ ឬ/និងរវាងអង្គការអន្តរជាតិ និងអង្គការអន្តរជាតិ។

# សញ្ញាណទូទៅ

សន្ធិសញ្ញាដែលជាកិច្ចព្រមព្រៀងអន្តរជាតិនេះ ដាច់ខាតត្រូវតែស្រប (ចែងឡើងដោយច្បាប់) ច្បាស់អន្តរជាតិ។ ទន្ទឹមនឹងគ្នានេះដែរ កិច្ចព្រមព្រៀងអន្តរជាតិអាចត្រូវបានធ្វើឡើងក្នុងទម្រង់ផ្សេងៗគ្នា និងវាក៏អាចត្រូវបានគេដាក់ឈ្មោះវាផ្សេងគ្នាបានផងដែរ។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

កិច្ចព្រមព្រៀងអន្តរជាតិ អាចត្រូវបានគេដាក់ឈ្មោះផ្សេងៗ ឬ វាត្រូវបានគេបង្កើតឡើងនៅក្នុងទម្រង់ផ្សេងៗគ្នា ដែលរួមមានដូចជា៖ អនុសញ្ញា សន្ធិសញ្ញា ធម្មនុញ្ញ កិច្ចព្រមព្រៀងអន្តរជាតិ ពិធីសារ សេចក្តីប្រកាស អនុស្សរណៈនៃការយោគយល់ MODUS VIVENDI និងកំណាត់ប្តូរសារ ជាអាទិ៍។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

- អនុសញ្ញា

អនុសញ្ញាអាចត្រូវបានគេប្រើក្នុងន័យទូទៅ និងក្នុងន័យជាក់លាក់ (ក្នុងន័យពិសេស)។

ក. អនុសញ្ញាក្នុងន័យទូទៅ៖ គឺគ្រប់ដណ្តប់ទៅគ្រប់កិច្ចព្រមព្រៀងអន្តរជាតិទាំងអស់ ដែលវាក៏ត្រូវបានគេប្រើក្នុងន័យទូទៅដូចទៅនិងសន្ធិសញ្ញាដែរ។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

• អនុសញ្ញា

ខ. អនុសញ្ញាក្នុងន័យជាក់លាក់៖ គឺកាលពីដើមឡើយវាត្រូវបានគេប្រើសម្រាប់សំដៅទៅលើកិច្ចព្រមព្រៀងទ្វេរភាគី។ ពេលបច្ចុប្បន្ន វាត្រូវបានគេប្រើសម្រាប់សន្ធិសញ្ញាពហុភាគីដែលមានភាគីច្រើនចូលរួម ហើយជាធម្មតាបើកចំហរឲ្យមានការចូលរួមពីគ្រប់ភាគីក្នុងសង្គមអន្តរជាតិ ឬ ពីរដ្ឋភាគច្រើន។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

- អនុសញ្ញា

ខ. អនុសញ្ញាក្នុងន័យទូទៅ៖ ជាធម្មតា ពាក្យថាអនុសញ្ញាក្នុងន័យទូទៅ គឺជាលិខិតូបករណ៍ដែលត្រូវបានចរចាររៀបចំឡើងក្រោមការសម្របសម្រួលដោយអង្គការអន្តរជាតិ គឺត្រូវបានគេដាក់ឈ្មោះថា អនុស័ញ្ញា។ ឧទាហរណ៍ អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រឆ្នាំ១៩៨២ ជាអាទិ៍។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

- សន្ធិសញ្ញា

ពាក្យថាសន្ធិសញ្ញា អាចត្រូវបានគេប្រើក្នុងន័យទូទៅផងនិងក្នុងន័យជាក់លាក់ផងដែរ (ន័យពិសេស) ដែលសំដៅដល់លិខិតូបករណ៍មានចរិកលក្ខណៈជាក់លាក់មួយ។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

- សន្ធិសញ្ញា

ក. សន្ធិសញ្ញាក្នុងន័យទូទៅ៖ គឺសំដៅដល់លិខិតូបករណ៍ដែលបង្កើតអនុភាពគតិយុត្តជាអន្តរជាតិដែលត្រូវបានរៀបចំឡើងដោយតួអង្គនៃនីតិអន្តរជាតិ ដោយមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេឡើយ។ ក្នុងន័យទូទៅវាក៏ត្រូវគេប្រើដូចទៅនឹងពាក្យថាអនុសញ្ញាផងដែរ។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

- សន្ធិសញ្ញា

ក. សន្ធិសញ្ញាក្នុន័យទូទៅ៖ អនុសញ្ញាទាំងពីរខាងក្រោមនេះ ជាឧទាហរណ៍សម្រាប់បញ្ជាក់ពីការប្រើប្រាស់ពាក្យថា សន្ធិសញ្ញាក្នុងន័យទូទៅដូចទៅនិងអនុសញ្ញា គឺអនុសញ្ញាទីក្រុងវីយែន ១៩៦៩ និង អនុសញ្ញាវីយែន ១៩៨៦ ស្តីពីច្បាប់សន្ធិសញ្ញា។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

• សន្ធិសញ្ញា

ខ. សន្ធិសញ្ញាក្នុងន័យជាក់លាក់៖ ជាទូទៅគ្មានច្បាប់អន្តរជាតិណាមួយបានកំណត់ពីការប្រើប្រាស់ពាក្យស័ព្ទទាំងអស់នេះទេ នៅពេលដែលរដ្ឋប្រើប្រាស់ជាក់ស្តែងនូវពាក្យថា សន្ធិសញ្ញា ឬ អនុសញ្ញា ឬក៏ទម្រង់ផ្សេងទៀតនៃកិច្ចព្រមព្រៀងអន្តរជាតិ។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

- សន្ធិសញ្ញា

ខ. សន្ធិសញ្ញាក្នុងន័យជាក់លាក់៖ ជាធម្មតាពាក្យថាសន្ធិសញ្ញា ត្រូវបានគេប្រើជាលិខិតូបករណ៍អន្តរជាតិសំដៅបញ្ហាជាក់លាក់ណាមួយ។ ហើយជាធម្មតាសន្ធិសញ្ញាតម្រូវឲ្យមានការចុះហត្ថលេខា និង ផ្តល់សច្ចាប័ន។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

- សន្ធិសញ្ញា

ខ. សន្ធិសញ្ញាក្នុងន័យជាក់លាក់៖ គេនិយមប្រើពាក្យថាសន្ធិសញ្ញា សម្រាប់កម្មវត្ថុមួយចំនួនដូចជា សន្ធិសញ្ញាសន្តិភាព សន្ធិសញ្ញាព្រំដែន សន្ធិសញ្ញាកំណត់ព្រំដែន សន្ធិសញ្ញាបត្យាប័ន សន្ធិសញ្ញាមិត្តភាព សន្ធិសញ្ញាសហប្រតិបត្តិការពាណិជ្ជកម្ម ជាអាទិ៍។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

- ធម្មនុញ្ញ

ពាក្យថា ធម្មនុញ្ញត្រូវបានគេប្រើជាលិខិតូបករណ៍ដែលមានលក្ខណៈជាក់លាក់ និងប្រាកដប្រជា ហើយជាពិសេសគេនិយមប្រើពាក្យធម្មនុញ្ញសម្រាប់ជាសន្ធិសញ្ញាសម្រាប់បង្កើតអង្គការអន្តរជាតិ។ ឧទាហរណ៍ ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិឆ្នាំ១៩៤៥ ជាអាទិ៍។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

- កិច្ចព្រមព្រៀង

ពាក្យកិច្ចព្រមព្រៀង អាចត្រូវបានគេប្រើក្នុងន័យទូទៅ និងក៏ត្រូវបានគេប្រើក្នុងន័យពិសេសផងដែរ។ វាក៏អាចត្រូវបានគេយកទៅប្រើក្នុងន័យពិសេសសម្រាប់ជាបទដ្ឋានដែលទាក់ទងទៅនិងការរួមបញ្ចូលនូវសេដ្ឋកិច្ចថ្នាក់តំបន់ ជាអាទិ៍។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

- កិច្ចព្រមព្រៀងអន្តរជាតិ

ក. កិច្ចព្រមព្រៀងក្នុងន័យទូទៅ៖ អនុសញ្ញាទីក្រុងវីយែនឆ្នាំ ១៩៦៩ ក៏ត្រូវបានគេហៅថាជាកិច្ចព្រមព្រៀងអន្តរជាតិ។ ដូច្នេះពាក្យថាកិច្ចព្រមព្រៀងក្នុងន័យទូទៅ អាចត្រូវបានប្រើប្រាស់ក្នុងន័យទូលាយ ដែលសំដៅដល់បទដ្ឋានអន្តរជាតិ ដែលបម្រើផលប្រយោជន៍រួមរបស់មនុស្សជាតិ។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

- កិច្ចព្រមព្រៀងអន្តរជាតិ

ខ. កិច្ចព្រមព្រៀងក្នុងន័យជាក់លាក់៖ ពាក្យកិច្ចព្រមព្រៀង អាចមានលក្ខណៈផ្លូវការតិចតួចជាងសន្ធិសញ្ញា ឬ អនុសញ្ញា ហើយច្រើនប្រើសម្រាប់ដោះស្រាយបញ្ហាដែលមានលក្ខណៈចង្អៀតជាងសន្ធិសញ្ញា។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

- កិច្ចព្រមព្រៀងអន្តរជាតិ

ខ. កិច្ចព្រមព្រៀងក្នុងន័យជាក់លាក់៖ គេនិយមប្រើពាក្យថា កិច្ចព្រមព្រៀងចំពោះបញ្ហាមួយដូចជា សេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងកិច្ចសហប្រតិបត្តការបច្ចេកទេស។ ជាញឹកញាប់វាត្រូវបានគេប្រើសម្រាប់ ដោះស្រាយបញ្ហាហិរញ្ញវត្ថុ ដូចជាការធានាវិនិយោគ និងការយកពន្ធត្រួតគ្នាជាអាទិ៍។

# ទម្រង់ផ្សេងៗនៃកិច្ចព្រមព្រៀងអន្តរជាតិ

- ពិធីសារ

ពាក្យថាពិធីសារ មានលក្ខណៈផ្លូវការតិចតួចជាងសន្ធិសញ្ញាឬអនុសញ្ញា ហើយពិធីសារអាចត្រូវគេប្រើទៅតាមប្រភេទផ្សេងៗជាច្រើនដូចជា៖ ពិធិសារហត្ថលេខា ពិធីសារជម្រើស ពិធីសារវិសោធនកម្ម ពិធីសារផ្អែកលើទម្រង់របស់សន្ធិសញ្ញា ពិធីសារបំពេញបន្ថែម ជាអាទិ៍។

# ផ្នែកទី៣ ទំនៀមទំលាប់

មាត្រា៣៨ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិទទួលថាទំនៀមទំលាប់អន្តរជាតិ ក៏ជាប្រភពមួយដ៏សំខាន់នៃនីតិអន្តរជាតិសាធារណៈផងដែរ។ ទន្ទឹមនេះផងដែររដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ ក៏បានចាត់ទុកទំនៀមទំលាប់អន្តរជាតិថា ជាប្រភពចម្បងរបស់នីតិអន្តរជាតិសាធារណៈ ដូចថៅក្រមតុលាការយុត្តិធម៌អន្តរជាតិដែរ។

# សញ្ញាណទូទៅ

ទំនៀមទំលាប់អន្តរជាតិ អាចឲ្យគេទទួលស្គាល់បានលុះណាតែវាត្រូវមានធាតុផ្សំចំនួនពីរសំខាន់ៗ ដែលក្នុងនោះរួមមាន ធាតុផ្សំជាសម្ភារៈ និងធាតុផ្សំចិត្តវិទ្យា។ ប្រសិនបើយើងនិយាយពីធាតុផ្សំសម្ភារៈ សំដៅទៅលើកិច្ច និងបើយើងនិយាយពីធាតុផ្សំចិត្តវិទ្យាគឺសំដៅដល់លក្ខណៈចាប់បង្ខំ។ នៅក្នុងមេរៀនទី៥ នឹងធ្វើការបកស្រាយពន្យល់នូវធាតុផ្សំទាំងពីរនេះ។

# ផ្នែកទី៤ គោលការណ៍ទូទៅនៃនីតិ

គោលការណ៍ទូទៅនៃនីតិ ក៏ត្រូវបានចាត់ទុកថាជាប្រភពមួយដែរនៃនីតិអន្តរជាតិសាធារណៈ តែវាពុំមែនជាប្រភពចម្បងនោះឡើយ គឺវាជាប្រភពបន្ទាប់បន្សំនៃនីតិអន្តរជាតិសាធារណៈ។ គេអះអាងថា គោលការណ៍ទូទៅនៃនីតិអន្តរជាតិ គឺជាគ្រោងឆ្អឹងនៃនីតិអន្តរជាតិសាធារណៈ។

# សញ្ញាណទូទៅ

ចំណែកឯយុត្តិសាស្ត្រ និងទ្រឹស្តីវិទូនៃនីតិអន្តរជាតិមិនមែនជាប្រភពនៃនីតិអន្តរជាតិសាធារណៈឡើយ។ នោះក៏ព្រោះតែយុត្តិសាស្ត្រ អាចត្រូវបានយកមកប្រើបានតែក្នុងករណីដែលរឿងហេតុនោះដូចគ្នា។ ចំណែកឯទ្រឹស្តីវិទូ វាគ្រាន់តែជាការបកស្រាយនូវចំណុចវិជ្ជមាន ឬ អវិជ្ជមាននៃបទដ្ឋានអន្តរជាតិណាមួយដែលត្រូវបានគេបង្កើតឡើង។

# ផ្នែកទី៥ កិច្ចឯកតោភាគី

ទោះបីជា កិច្ចឯកតោភាគីបានធ្វើឲ្យប៉ះពាល់ដល់លក្ខណៈនៃការព្រមព្រៀងនិយមក៏ដោយ ក៏កិច្ចឯកតោភាគីអាចចូលរួមបង្កើតបានជាវិធាននៃនីតិអន្តរជាតិមួយបានផងដែរ។ កិច្ចឯកតោភាគី គឺជាអំពើពិត អាកប្បកិរិយាពិតរបស់តួអង្គនៃនីតិអន្តរជាតិដែលធ្វើឲ្យទំនាក់ទំនងជាមួយភាគីម្ខាងទៀត។

# សញ្ញាណទូទៅ

កិច្ចឯកតោភាគី គឺជាកិច្ច ឬសកម្មភាពមួយដែលតាមរយៈសកម្មភាពរបស់ភាគីតែម្ខាង តែវាបានបង្កឲ្យមានជាបទដ្ឋានដែលឈានទៅបង្កើតឲ្យមានសិទ្ធិ និងបង្កើតកាតព្វកិច្ចតាមផ្លូវច្បាប់ ហើយដែលវាបានធ្វើឲ្យមានចំណាប់អារម្មណ៍ដល់តួអង្គនៃនីតិអន្តរជាតិផ្សេងទៀត។

# សញ្ញាណទូទៅ

កិច្ចឯកភាគី អាចជាកិច្ច ឬសកម្មភាពរបស់រដ្ឋ ឬ/និងកិច្ចរបស់អង្គការអន្តរជាតិ។ កិច្ចឯកតោភាគី ត្រូវគោរពនូវលក្ខខណ្ឌសុពលភាពដូចជា៖ កិច្ចនោះត្រូវតែធ្វើឡើងដោយអាជ្ញាធរដែលតំណាងឲ្យក្នុងទំនាក់ទំនងអន្តរជាតិ កិច្ចនោះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ កិច្ចនេះមិនត្រូវមានការជំទាស់ កិច្ចត្រូវធ្វើឡើងក្នុងទំនាក់ទំនងអន្តរជាតិ និងចុងក្រោយកិច្ចនេះត្រូវតែស្របច្បាប់។

មេរៀនទី២ ត្រូវបានបញ្ចប់ សូមអរគុណសម្រាប់ការតាមដាន ដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។